អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## ចក្រភពអង់គ្លេសសន្យាផ្តល់ជំនួយថវិកាបន្ថែមចំនួន ៦សែនផោន ដល់ អ.វ.ត.ក

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថ្លែងអំណរគុណចំពោះរដ្ឋាភិបាលនៃចក្រភពអង់គ្លេស ដែលបានសន្យាផ្តល់ជំនួយថវិកាបន្ថែមចំនួន ៦០០.០០០ ផោន (ប្រមាណ ១លាន ដុល្លារអាមេរិក) ដល់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។

រដ្ឋមន្ត្រីក្រសួងការបរទេសនៃចក្រភពអង់គ្លេស លោក វីល្លៀម ហេក (William Hague) បានប្រកាសអំពីវិភាគទានស្ម័គ្រចិត្តនេះ នៅក្នុងសេចក្តីប្រកាសថ្ងៃទី១៣ ខែធ្នូ ដោយលើកឡើងថា ជំនួយថ្មីនេះនឹងធានាឲ្យមានការដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងប្រវត្តិសាស្ត្រដែលទើបតែកន្លងផុតទៅ។

លោក ហេក បានថ្លែងថា “អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងតែនាំយកយុត្តិធម៌មកជូនប្រជាជនកម្ពុជារាប់លាននាក់ដែលបានរង់ចាំអស់ពេលជាយូរមកហើយ។ ទំហំនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត និងចំនួននៃជនរងគ្រោះ បានធ្វើឲ្យតុលាការនេះក្លាយជាតុលាការដ៏ពិសេសបំផុត ចាប់តាំងពីមានតុលាការ នូរិមប៊ឺក មក”។

ចក្រភពអង់គ្លេសបានផ្តល់ជំនួយថវិកាដល់ អ.វ.ត.ក សរុបចំនួន ៦,៩៥ លានដុល្លារអាមេរិក (ក្នុងនោះ ៥,៤ លានដុល្លារសម្រាប់ភាគីអន្តរជាតិ និង ១,៥លានដុល្លារ សម្រាប់ភាគីជាតិ) ចាប់តាំងពីការចាប់បដិសន្ធិនៃតុលាការនេះនៅឆ្នាំ២០០៦មក។ បូករួមទាំងការសន្យាថ្មីនេះ ជំនួយសរុបរបស់ចក្រភពអង់គ្លេសឡើងដល់ ៧,៩ លានដុល្លារ។

ប្រធានការិយាល័យរដ្ឋបាលស្តីទី ឯកឧត្តម ក្រាញ់ តូនី និងមន្ត្រីទទួលបន្ទុកការិយាល័យអនុប្រធានរដ្ឋបាល លោក វ៉ាជីវ គុមវ៉ា បានឆ្លើយតប ចំពោះទឹកចិត្តសប្បុរសនេះថា៖ “តាងនាម អ.វ.ត.ក យើងខ្ញុំសូមសម្តែងអំណរគុណចំពោះការសន្យាថ្មីនេះរបស់រដ្ឋាភិបាលចក្រភពអង់គ្លេស ដែលធ្វើឡើងចំពេលដែល អ.វ.ត.ក ជួបប្រទះកង្វះខាតថវិកា”។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោកស្រី យូកូ ម៉ៃដា**
មន្ត្រីកិច្ចការសាធារណៈ:
ទូរស័ព្ទចល័តៈ +៨៥៥ (0) ១២ ៤៨៨ ៣១៩
ទូរស័ព្ទលើតុ: +៨៥៥ (0) ២៣ ៨៦១ ៦៣៩
សារអេឡិកត្រូនិក: maeday@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh